ប្រធានក្រុមការងារអន្តរក្រសួង អាចស្នើសុំមន្ត្រីនៃទីស្តីការក្រសួងមហាផ្ទៃ ឬមន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងក្រុមការងារអន្តរក្រសួង ឱ្យជួយការងារតាមការចាំបាច់ តាមការសម្រេចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីនៃក្រសួង ឬប្រធានស្ថាប័នពាក់ព័ន្ធទាំងនោះ។

ប្រការ ៥.-

ក្នុងការសម្របសម្រួលរៀបចំខ្លឹមសារនៃកិច្ចប្រជុំ ក្រុមការងារអន្តរក្រសួងមានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធឱ្យចូលរួម តាមការចាំបាច់។

ប្រការ ៦.-

ក្រុមការងារអន្តរក្រសួងមានសិទ្ធិប្រើប្រាស់ត្រា និងប្រើប្រាស់ថវិការបស់ក្រសួងមហាផ្ទៃក្នុងការចាត់ចែងការងាររបស់ខ្លួន។

ប្រការ ៧.-

ក្រុមការងារអន្តរក្រសួងបញ្ចប់កិច្ចការរបស់ខ្លួន បន្ទាប់ពីបានធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំជូនប្រមុខរាជរដ្ឋាភិបាលរួចរាល់ជាស្ថាពរ។

ប្រការ ៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធានគណៈកម្មាធិការចំរុះកិច្ចការព្រំដែន រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អភិបាលនៃគណៈអភិបាលខេត្តជាប់ព្រំដែនជាមួយប្រទេសវៀតណាម និងឯកឧត្តមដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៧. សសរ

សេចក្តីសម្រេច
ស្តីពី
ការបង្កើតគណៈកម្មការរៀបចំការប្រកួតកីឡាតំបន់ឆ្នេរ ខេត្តព្រះសីហនុ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងសំណូមពរការងារចាំបាច់

សម្រេច

ប្រការ១: ត្រូវបានបង្កើតគណៈកម្មការរៀបចំការប្រកួតកីឡាតំបន់ឆ្នេរ ខេត្តព្រះសីហនុ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១២ និងជារៀងរាល់ឆ្នាំបន្តបន្ទាប់ មានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម	**ថោង ខុន**	រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា	**ប្រធាន**
២- ឯកឧត្តម	**ប៊ុន សុខ**	រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា , អនុប្រធានទី២ គ.ជ.អ.ក និងជាប្រធានសហព័ន្ធខ្មែរកីឡាអត្តពលកម្មស្ម័គ្រចិត្ត	**អនុប្រធាន**
៣- ឯកឧត្តម	**ឈៀង សារ៉ាត់**	អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ	**អនុប្រធាន**
៤- ឯកឧត្តម	**ហោ សារុន**	អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍	**អនុប្រធាន**
៥- ឯកឧត្តម	**ស៊ឹន សុខន**	អភិបាលរងនៃគណៈអភិបាលខេត្តព្រះសីហនុ	**អនុប្រធាន**
៦- លោក	**វ៉ាត់ ចំរើន**	អគ្គលេខាធិការគ.ជ.អ.ក	**អនុប្រធានអចិន្ត្រៃយ៍**
៧- ឯកឧត្តម	**ឡាយ ឫទ្ធី**	អគ្គនាយករងនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករ	**សមាជិក**

p

៨-	ឧ.ឧត្តមសេនីយ៍ត្រី **តាក់ វណ្ណថា**	ស្នងការនគបាលខេត្តព្រះសីហនុ	**សមាជិក**
៩-	ឧ.ឧត្តមសេនីយ៍ត្រី **ហ៊ាង ធីន**	មេបញ្ជាការកងរាជអាវុធហត្ថខេត្តព្រះសីហនុ	**សមាជិក**
១០-	លោក HIDETOSHI OCHIAI	នាយកក្រុមហ៊ុន CEO Co., Ltd.	**សមាជិក**
១១-	លោក **សែម ផល្លា**	នាយករងក្រុមហ៊ុន CEO Co., Ltd.	**សមាជិក**
១២-	លោក **ជិន សារិន**	អភិបាលនៃគណៈអភិបាលក្រុងព្រះសីហនុ	**សមាជិក**
១៣-	លោក **វ៉ាត់ ឈួន**	អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះសីហនុ	**សមាជិក**
១៤-	លោក **ជា ប៊ុនភៀង**	ប្រធានការិយាល័យកីឡានៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះសីហនុ	**សមាជិក**
១៥-	លោក **សេង ខា**	ប្រធានស្តីទីមន្ទីរទេសចរណ៍ខេត្តព្រះសីហនុ	**សមាជិក**
១៦-	លោក **វ៉ាត់ ស្រ៊ុន**	តំណាង គ.ជ.អ.ក ប្រចាំខេត្តព្រះសីហនុ	**សមាជិក**

ប្រការ២: គណៈកម្មការរៀបចំការប្រកួតកីឡាតំបន់ឆ្នេរ ខេត្តព្រះសីហនុមានមុខងារ និងភារកិច្ចដូចតទៅ៖

- រៀបចំកម្មវិធី និងការផ្សព្វផ្សាយ
- រៀបចំបដិសណ្ឋារកិច្ចស្វាគមន៍ ការធ្វើដំណើរ ហូបចុកស្នាក់នៅ
- ជួយសម្រួលបែបបទធ្វើដំណើរ បែបបទគយជូនដល់គណៈប្រតិភូកីឡា តាមច្រកទ្វារព្រំដែនអន្តរជាតិនានា ទាំងពេលធ្វើដំណើរ មកដល់ និងត្រឡប់វិញ។

ប្រការ៣: គណៈកម្មការនេះមានលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានទីតាំងនៅគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា មានសមាសភាពដូចខាងក្រោម៖

១-	លោក **វ៉ាត់ ចំរើន**	អគ្គលេខាធិការ គ.ជ.អ.ក	**ប្រធាន**
២-	លោក **សែម ផល្លា**	នាយករងក្រុមហ៊ុន CEO Co., Ltd.	**អនុប្រធាន**
៣-	លោក **ម៉ែន វុទ្ធី**	អគ្គលេខាធិការសហព័ន្ធកីឡាអត្តពលកម្មស្ម័គ្រចិត្ត	**អនុប្រធាន**
៤-	លោក **ហែម សំណាង**	អគ្គលេខាធិការរង គ.ជ.អ.ក	**សមាជិក**
៥-	លោក **ហែម ថុន**	ប្រធាន៧.រដ្ឋបាល គ.ជ.អ.ក	**សមាជិក**
៦-	លោក **ណយ ផាណា**	ប្រធាន៧.ទំ/ទំ និងសហប្រតិបត្តិការអន្តរជាតិ គ.ជ.អ.ក	**សមាជិក**
៧-	លោក **កាំង សុផា**	ប្រធាន៧.ទីផ្សា និងផ្សព្វផ្សាយ គ.ជ.អ.ក	**សមាជិក**
៨-	លោក **តុប បញ្ញា**	ប្រធានគណនេយ្យ គ.ជ.អ.ក	**សមាជិក**
៩-	លោក **ឈួន ឡេង**	អនុប្រធាន៧.រដ្ឋបាល គ.ជ.អ.ក	**សមាជិក**
១០-	លោក **ម៉ុយ ឡាត**	ប្រធានប្រព័ន្ធ IT កីឡា	**សមាជិក**

ប្រការ៤: លេខាធិការដ្ឋាននេះមានមុខងារ និងភារកិច្ចដូចតទៅ៖

- សំរបសំរួលការងារប្រជុំ និងព្រឹត្តិការណ៍ប្រកួត។

p

- ធ្វើការរៀបចំស្ប៉តផ្សព្វផ្សាយតាមបណ្តាញព័ត៌មានក្នុងប្រទេស និងក្រៅប្រទេស ជាពិសេសតាមវិទ្យុ ទូរទស្សន៍ ដើម្បីឱ្យសាធារណជនបានយល់ជ្រួតជ្រាប និងចូលរួមក្នុងព្រឹត្តិការណ៍ប្រកួត ។
- ជ្រើសរើសកីឡាករ-ការិនីកម្ពុជា ដើម្បីចូលរួមប្រកួតជាមួយកីឡាករបរទេស ។
- រៀបចំ និងជួយសម្រួលបែបបទនៃការធ្វើដំណើរ និងបែបបទគយនៅតាមច្រកទ្វារព្រំដែនអន្តរជាតិនានា កន្លែងស្នាក់នៅ ហូបចុកជូនគណៈប្រតិភូ និងកីឡាករ-ការិនីអន្តរជាតិ
- រៀបចំពិធីបើក-បិទតាមដំណាក់កាលប្រកួត និងពិធីជប់លៀងផ្សេងៗ ។
- ធ្វើរបាយការណ៍បូកសរុបអំពីលទ្ធផលនៃការរៀបចំ និងកិច្ចដំណើរការនៃការប្រកួតកីឡាតំបន់ឆ្នេរ ជូនថ្នាក់ដឹកនាំ និងប្រមុខរាជរដ្ឋាភិបាល ។

ប្រការ៤: - គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រា និងថវិកាបន្ថែមរបស់គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជាក្នុងករណីចាំបាច់ ។

- គណៈកម្មការនេះមានសិទ្ធិជ្រើសរើសកន្លែងប្រើប្រាស់មន្ត្រីពាក់ព័ន្ធក្រោមឱវាទក្នុងករណីចាំបាច់ ។

ប្រការ៥: - សមាជិកនៃគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

- គណៈកម្មការនេះនឹងត្រូវរំសាយក្រោយពេលចប់ភារកិច្ច ។

ប្រការ៦: បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៧: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា អគ្គស្នងការនគរបាលជាតិ អគ្គនាយកគយ និងរដ្ឋាករកម្ពុជា ព្រមទាំងសាមីខ្លួនដែលមានចែងក្នុង**ប្រការ១** និង**ប្រការ៣** ត្រូវអនុវត្ត សេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៧
-ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

លេខ : ០០១ [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១២

ប្រកាស

ស្តីពីការដាក់ឈ្មោះរោងចក្រ និង សិប្បកម្ម

រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម//០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញប្រកាសលេខ ៦០៧ ឧរថប្រក.អឧ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីនីតិវិធី និងបែបបទស្នើសុំបង្កើតរោងចក្រ និងសិប្បកម្ម
- បានឃើញប្រកាសលេខ ២៤២ ឧរថ.កឧ.ប្រក ចុះថ្ងៃទី០៤ ខែមិនា ឆ្នាំ២០១១ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីនីតិវិធីអនុវត្តបទប្បញ្ញត្តិលើកិច្ចដំណើរការរោងចក្រ និងសិប្បកម្ម
- យោងតាមសំណូមពរចាំបាច់របស់ក្រសួង

សម្រេច

ប្រការ១: គោលបំណង

ដើម្បីជំរុញកិច្ចដំណើរការរោងចក្រនិងសិប្បកម្ម ឱ្យអនុលោមទៅតាម ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រនិងសិប្បកម្ម និង ប្រកាសស្តីពីនីតិវិធីអនុវត្តបទប្បញ្ញត្តិលើកិច្ចដំណើរការរោងចក្រនិងសិប្បកម្ម រោងចក្រនិងសិប្បកម្មទាំងអស់ត្រូវមានឈ្មោះរបស់ខ្លួន ។

គោលបំណងនៃការដាក់ឈ្មោះរោងចក្រនិងសិប្បកម្ម គឺដើម្បីៈ

- ប្រសិទ្ធិភាពការងារគ្រប់គ្រងរោងចក្រនិងសិប្បកម្ម

p

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១. ទូរសារ : ៨៥៥ ២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh Phnom Penh, Phone 855-23-211141, Fax : 855-23-428263

- ពង្រឹងការទទួលខុសត្រូវរបស់ម្ចាស់រោងចក្រនិងសិប្បកម្ម ក្នុងការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនានា
- បង្កើនប្រសិទ្ធិភាពធុរកិច្ច និងកិច្ចទំនាក់ទំនង

ប្រការ២: ការដាក់ឈ្មោះរោងចក្រនិងសិប្បកម្ម

ម្ចាស់រោងចក្រនិងសិប្បកម្ម ត្រូវប្រកាសអំពីឈ្មោះរោងចក្រនិងសិប្បកម្មរបស់ខ្លួន នៅពេលដាក់ពាក្យស្នើសុំបង្កើតរោងចក្រនិងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬ ចុះបញ្ជីនៅមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី-ខេត្ត។

ប្រការ៣: ទម្រង់ឈ្មោះរោងចក្រនិងសិប្បកម្ម

ឈ្មោះរោងចក្រ និងសិប្បកម្ម ត្រូវសរសេរជាអក្សរខ្មែរមានអក្ខរាវិរុទ្ធត្រឹមត្រូវ ដោយបញ្ជាក់អំពីមុខផលិតកម្មសំខាន់របស់ខ្លួននៅខាងដើម ។ ម្ចាស់រោងចក្រ និងសិប្បកម្ម អាចសរសេរឈ្មោះរោងចក្រនិងសិប្បកម្ម ជាអក្សរបរទេសបន្ថែម ក៏ប៉ុន្តែឈ្មោះជាអក្សរបរទេសត្រូវតែមានទំហំតូចជាង និងនៅពីក្រោមឈ្មោះជាអក្សរខ្មែរ និងមានន័យដូចគ្នា។

ប្រការ៤: ផ្លាកឈ្មោះរោងចក្រនិងសិប្បកម្ម

ម្ចាស់រោងចក្រ និងសិប្បកម្ម ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្រនិងសិប្បកម្ម ដែលសរសេរជាអក្សរខ្មែរមានទំហំធំជាងនិងនៅលើអក្សរផ្សេងទៀត ដូចបានបញ្ជាក់នៅប្រការ៣ ខាងលើ នៅកន្លែងងាយមើលឃើញមុខរោងចក្រ និងសិប្បកម្ម ។ ផ្លាកឈ្មោះរោងចក្រនិងសិប្បកម្ម ត្រូវមានទំហំសមាមាត្រទៅនឹងទីតាំងរោងចក្រនិងសិប្បកម្ម ដើម្បីងាយមើលឃើញ ។

ប្រការ៥: ការផ្លាស់ប្តូរឈ្មោះរោងចក្រ និងសិប្បកម្ម

ក្នុងករណីមានការផ្លាស់ប្តូរឈ្មោះរោងចក្រនិងសិប្បកម្ម ម្ចាស់រោងចក្រនិងសិប្បកម្ម ត្រូវធ្វើសេចក្តីជូនដំណឹងអំពីឈ្មោះថ្មីជាលាយលក្ខអក្សរមក ក្រសួង ឬ មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបាន១០(ដប់) ថ្ងៃ មុនថ្ងៃប្រើប្រាស់។

បន្ទាប់ពីបានជូនដំណឹង ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រនិងសិប្បកម្ម ត្រូវលើកបង្ហាញផ្លាកឈ្មោះថ្មី នៅខាងមុខរោងចក្រនិងសិប្បកម្ម។

ប្រការ៦: ទោសប្បញ្ញត្តិ

ការប្រព្រឹត្តល្មើសទៅនឹងមាត្រា១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រនិងសិប្បកម្ម ឬ អនុវត្តផ្ទុយទៅនឹងបទបញ្ជានេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០ រៀល(ពីរលានរៀល) ទៅ ១០.០០០.០០០ រៀល (ដប់លានរៀល)។

ប្រការ៧: អន្តរប្បញ្ញត្តិ

រោងចក្រនិងសិប្បកម្ម ដែលមិនទាន់មានឈ្មោះ ឬ មិនទាន់បានដាក់តាំងបង្ហាញផ្លាកឈ្មោះរោងចក្រនិងសិប្បកម្មនៅឡើយ ត្រូវប្រកាសឈ្មោះរោងចក្រនិងសិប្បកម្ម របស់ខ្លួន តាមរយៈសេចក្តីជូនដំណឹងមកក្រសួង ឬមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល និង ត្រូវដាក់តាំងបង្ហាញផ្លាកឈ្មោះរោងចក្រនិងសិប្បកម្ម ដូចមានចែងក្នុងប្រការ៤ ខាងលើ ក្នុងរយៈពេល ៦០(ហុកសិប) ថ្ងៃ យ៉ាងយូរ ចាប់ពីថ្ងៃចុះហត្ថលេខាលើបទបញ្ជា នេះតទៅ ។

ទំ ២

p

ប្រការ៩: អវសានប្បញ្ញត្តិ

អគ្គនាយកដ្ឋានឧស្សាហកម្ម វិទ្យាស្ថាន នាយកដ្ឋាន អង្គភាពចំណុះអគ្គនាយកដ្ឋានឧស្សាហកម្ម អង្គភាពចំណុះក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី-ខេត្ត រោងចក្រនិងសិប្បកម្មទាំងអស់ ត្រូវអនុវត្តបទបញ្ជានេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ។

រដ្ឋមន្ត្រី

ស៊ុយ សែម

__ចម្លងជូន:__
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងព័ត៌មាន
- ក្រសួងបរិស្ថាន
- ក្រសួងយុត្តិធម៌
- គ្រប់សាលារាជធានី-ខេត្ត
- គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី-ខេត្ត "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៤០១ ពណ.ចបព

ភ្នំពេញថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម

១- នាមករណ៍របស់ក្រុមហ៊ុន : **ដ្រេហ្គន សឺវីស ប្រូវ៉ាយឌើរ**
DRAGON SERVICE PROVIDER Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ២៣៣៨KH/២០១០ ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **គុយ ចាន់អួន**

៣- ដើមទុនក្រុមហ៊ុន : ២.០០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៣C ប្លុក ៨៣៦ ផ្លូវលេខ ២៤៥ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ រាហរណ៍ទំនិញគ្រប់ប្រភេទ
-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការវេចខ្ចប់សំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

p

៦- ចិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានភារកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ
កឹម ស៊ីថន

ចម្លងជូន
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

សសរ - ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៤០៤ **ពណ.ចបព**

ភ្នំពេញថ្ងៃទី ២៨ **ខែ** វិច្ឆិកា **ឆ្នាំ** ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោមៈ

១- នាមករណ៍របស់ក្រុមហ៊ុន : **ប៉ូ រីសសស៍ (ខេមបូឌា)**
POH RESOURCES (CAMBODIA) Ltd
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ២៣៨៨ E/២០១០ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១០
មានទម្រង់ជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក POH KAY PING

៣- ដើមទុនក្រុមហ៊ុន : ២០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : អគារហុងកុងសេនធ័រ វិថីសម្តេចសុធារស សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ និហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ -នាំចូលឱសថនិងសំភារៈ បរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាកែការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកុងតឺន័រឡើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ផ្លូវ
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

p

៦-ថិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានភារកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចាម ប្រសិទ្ធ

<u>ចម្លងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងព័ត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ម - ឯកសារ - កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៤០៥ ពណ.ចបព

ភ្នំពេញថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោមៈ

១- នាមករណ៍របស់ក្រុមហ៊ុន : **ជេ អិម វ៉ាយ អ៊ិនវេសមេន**
J M Y INVESTMENT Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ២៣០៧KH/២០១០ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១០
មានទម្រង់ច្បាប់ជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត
២- អភិបាលក្រុមហ៊ុន : លោកស្រី JANG MIYOUNG ប្រធានក្រុមប្រឹក្សាភិបាល
លោក **លី ដានីញ៉ែល** អភិបាល
៣- ដើមទុនក្រុមហ៊ុន : ២០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៧២ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ
៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ- នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

p

វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានភារកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

...ស៊ីថន

ចម្លងជូន
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានពន្ធដារ និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ក.ស.ឧ - ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៤០៧ **ពណ.ចបព**

ភ្នំពេញថ្ងៃទី ២៩ **ខែ** វិច្ឆិកា **ឆ្នាំ** ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ជាបុត្រសម្ព័ន្ធនៃក្រុមហ៊ុន SAFE ID Solutions AG (Germany) ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម:

១- នាមករណ៍របស់ក្រុមហ៊ុន : **សេហ្វ-អាយឌី (ខេមបូឌា) លីមីធីត**
Safe-ID (Cambodia) Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ២៣២៦ E/២០១០ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១០
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក MATTHIAS KARL KÖHLER " គតិយជន " ប្រធានក្រុមប្រឹក្សាភិបាល
លោក MANUEL JOHANNES KLEIN " គតិយជន " អភិបាល

៣- ដើមទុនក្រុមហ៊ុន : ៤.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៣៥ វិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ផ្តល់សេវាផ្នែកពត៌មានវិទ្យា
-ការផ្គូលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការផ្គត់ផ្គង់សំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

p

៦- ចិរវេលា . ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
[illegible]

ចម្លងជូន
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងព័ត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

សម - ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៤០៤ ពណ.ចបព

ភ្នំពេញថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១០

ឯកសាររដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោមៈ

១- នាមករណ៍របស់ក្រុមហ៊ុន	:	**ធី អេច អាយ ឌី គ្លូប៊ល អ៊ីមផត អិចផត** **T H I D GLOBAL IMPORT EXPORT Co., Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម	:	Co. ២៣៣២E/២០១០ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១០
មានទម្រង់ជា	:	ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត
២- អភិបាលក្រុមហ៊ុន	:	លោក LE VAN HIEU ប្រធានក្រុមប្រឹក្សាភិបាល លោក LY NGOC THANH អភិបាល លោក NGUYEN BA LUC អភិបាល
៣- ដើមទុនក្រុមហ៊ុន	:	៨០០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន	:	លេខ ៣២ ផ្លូវលេខ ៧០ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។
៥- កម្មវត្ថុអាជីវកម្ម	:	-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ -នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ -លក់គ្រឿងសំណង់គ្រប់ប្រភេទ -ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ -ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ -មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ -បើកសាលារៀន -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម -សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម -សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស -សេវាផ្សាយពាណិជ្ជកម្ម -បោះពុម្ពផ្សាយ -ផលិតខ្សែភាពយន្ត វីដេអូ CD -ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ -សេវាយកកំរៃជើងសាលើការដឹកជញ្ជូន -សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់ -ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត -វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ -វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម។

p

៦- ចិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

កឹម_ស៊ីថន

ចម្លងជូន
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស។ - ឯកសារ - កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៤១៧ **ពណ.ចបព**

ភ្នំពេញថ្ងៃទី២៩ **ខែ**វិច្ឆិកា **ឆ្នាំ** ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ជំរាបមក

លោក **សំណាង សីម៉ា** ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន **សីលាដាមិច អ៊ីមផត អិចផត**
អាសយដ្ឋាន: លេខ ២ ផ្លូវលេខ ៥៩២ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

កម្មវត្ថុ: ករណីសុំកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **សីលាដាមិច អ៊ីមផត អិចផត**
SELADAMEX IMPORT EXPORT Co., Ltd.

យោង : -សំណើរបស់ក្រុមហ៊ុន ចុះថ្ងៃទី ១៧ - ១១ - ២០១០
-កំណត់ហេតុអង្គប្រជុំ និងសេចក្តីសំរេចសមូហភាព ចុះថ្ងៃទី ១១ - ១១ - ២០១០
-លក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុនចុះហត្ថលេខា ថ្ងៃទី ១១ - ១១ - ២០១០
-សេចក្តីប្រកាសស្តីពីការកែប្រែលក្ខន្តិកៈក្រុមហ៊ុនក្នុងព្រឹត្តិប័ត្រពាណិជ្ជកម្មលេខ ៤២៧ ចេញផ្សាយថ្ងៃទី ១៥ - ១២ - ២០១០

តាមកម្មវត្ថុនិងយោងខាងលើនេះ ខ្ញុំសូមជំរាបលោកថា : ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីនូវការកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **សីលាដាមិច អ៊ីមផត អិចផត** SELADAMEX IMPORT EXPORT Co., Ltd. ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 12293/08P ចុះថ្ងៃទី 03 - 07 - 2008 ទៅតាមចំណុចដូចមានចែងក្នុងលិខិតស្នើ និងយោងខាងលើគឺ:

-ការលាលែងចេញសមាជិកហ៊ុនចំនួន ០១ រូប គឺលោក **ស៊ុំ សំណាង** " អភិបាលចាស់ "
-ការបញ្ចូលសមាជិកហ៊ុនថ្មីចំនួន ០១ រូប គឺលោកស្រី **ម៉ី ម៉ាន់ធា**
-ការធ្វើអនុប្បទានភាគហ៊ុន
-សមាសភាពសមាជិកហ៊ុនថ្មី :

-លោក **សំណាង សីម៉ា** (សញ្ជាតិ : ខ្មែរ) កាន់កាប់ភាគហ៊ុនចំនួន ១១៩ ភាគហ៊ុន
-កញ្ញា **សំណាង ផល្លា** (សញ្ជាតិ : ខ្មែរ) កាន់កាប់ភាគហ៊ុនចំនួន ៦៣ ភាគហ៊ុន
-លោកស្រី **ម៉ី ម៉ាន់ធា** (សញ្ជាតិ : ខ្មែរ) កាន់កាប់ភាគហ៊ុនចំនួន ៨១ ភាគហ៊ុន
-កញ្ញា **សំណាង ធីតា** (សញ្ជាតិ : ខ្មែរ) កាន់កាប់ភាគហ៊ុនចំនួន ៦៣ ភាគហ៊ុន
-លោក **ឆេព សំអាន** (សញ្ជាតិ : ខ្មែរ) កាន់កាប់ភាគហ៊ុនចំនួន ១៥ ភាគហ៊ុន
-លោក **គង់ ច័ន្ទ** (សញ្ជាតិ : ខ្មែរ) កាន់កាប់ភាគហ៊ុនចំនួន ១០ ភាគហ៊ុន
-លោក **ដួង ទ៉ារី** (សញ្ជាតិ : ខ្មែរ) កាន់កាប់ភាគហ៊ុនចំនួន ០៥ ភាគហ៊ុន
-លោក **ប៉ាន់ គឹមសាន** (សញ្ជាតិ : ខ្មែរ) កាន់កាប់ភាគហ៊ុនចំនួន ០១ ភាគហ៊ុន

- ការតែងតាំងក្រុមប្រឹក្សាភិបាលថ្មី:
  - លោក **សំណាង សីម៉ា** ប្រធានក្រុមប្រឹក្សាភិបាល
  - កញ្ញា **សំណាង ផល្លា** អភិបាល

ប៉ុន្តែក្រុមហ៊ុនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ប្រសិនជាមានការតវ៉ាណាមួយទាក់ទងនឹងការកែប្រែលក្ខន្តិកៈក្រុមហ៊ុននេះ ។

អាស្រ័យហេតុនេះ សូមលោកជ្រាប និងអនុវត្តស្របទៅតាមច្បាប់ជាធរមាន។

ជ. ទេសរដ្ឋមន្ត្រី
ក្រសួងពាណិជ្ជកម្ម

ស៊ីថន

ចម្លងជូន :

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងបរិស្ថាន
-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ធនាគារជាតិនៃកម្ពុជា
-ក្រសួងសុខាភិបាល
-ក្រសួងពត៌មាន
-ក្រសួងសាធារណការ និងដឹកជញ្ជូន
-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
-ក្រសួងអប់រំយុវជន និងកីឡា
-ក្រសួងទេសចរណ៍
-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
-អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
-មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ "
សជ -ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៤៤.១៤ ពណ.ចបព

ភ្នំពេញថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយជាបុត្រសម្ព័ន្ធនៃក្រុមហ៊ុន BEST ADVANCE RESOURCES LIMITED (BVI) ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម:

១- នាមករណ៍របស់ក្រុមហ៊ុន : **ហ្គ្រេត ផ្លេនថេសិន**
GREAT PLANTATIONS Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ២៣៦៧E/២០១០** ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១០
មានទម្រង់ជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក LIM WEE CHAI "គតិយជន" ប្រធានក្រុមប្រឹក្សាភិបាល
លោក LEE KIM MEOW "គតិយជន" អភិបាល
លោក LIM CHEONG GUAN "គតិយជន" អភិបាល
លោក HOO SAW HO "គតិយជន" អភិបាល
លោក GAN KWANG SIANG "គតិយជន" អភិបាល

៣- ដើមទុនក្រុមហ៊ុន : ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : SUITE ២៤ សណ្ឋាគារ កាំបូឌីយ៉ាណា លេខ ៣១៣ វិថីព្រះស៊ីសុវត្ថិ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ
-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការផ្ទុលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការផ្ទុសផុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ញើ និងបែងចែកទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន

p

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ . សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចាម_ប្រសិទ្ធ

ចម្លងជូន
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសោភ័ណ្ឌទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

សសរ - ឯកសារ - កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៤១៤ **ពណ.ចបព**

ភ្នំពេញថ្ងៃទី ៣០ **ខែ** វិច្ឆិកា **ឆ្នាំ** ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយជាបុត្រសម្ព័ន្ធនៃក្រុមហ៊ុន GRAIN MINERAL RESOURCES PTE. LTD. (សិង្ហបុរី) ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោមៈ

១- នាមករណ៍របស់ក្រុមហ៊ុន : **ជីអិមអរ (ខេមបូឌា) ប្រាយវេត លីមីធីត ខមភេនី**
GMR (CAMBODIA) PRIVATE LIMITED COMPANY

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ២៣៦៤E/២០១០** ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក RUDY HALIM "តតិយជន" ប្រធានក្រុមប្រឹក្សាភិបាល
លោក LIM KHONG SHEE "តតិយជន" អភិបាល

៣- ដើមទុនក្រុមហ៊ុន : ២០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : បន្ទប់ B ៤ ជាន់ទី ១ អគារ CBM លេខ ៣៥-៣៧ ផ្លូវលេខ ២១៤ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម :
-ធ្វើពាណិជ្ជកម្ម និងវិនិយោគលើផលិតផលកសិកម្ម
-ផ្តល់សេវាកម្មពិគ្រោះយោបល់ និងគ្រប់គ្រងផ្នែកពាណិជ្ជកម្ម -អាជីវកម្មទូទៅ ហិរញ្ញវត្ថុ ទេសចរណ៍ សំណង់ និងវិនិយោគ
-នាំចូលនូវម៉ាស៊ីន និងសម្ភារៈកសិកម្មផ្សេងៗសំរាប់បំរើឱ្យការដាំដុះ
-ផ្តល់សេវាកម្មក្នុងការជ្រើសរើស បណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្ស
-រកការងារជូនអតិថិជនក្នុង និងក្រៅប្រទេស
-ផ្តល់សេវាកម្មផ្នែករដ្ឋបាល ការងារការិយាល័យ លេខាធិការ និងបកប្រែ
-ទិញ លក់ ឬផ្លាស់ប្តូរទំនិញ នីហារ៍ណ អាហារ៍ណ ផ្គត់ផ្គង់ផលិតផលទំនិញគ្រប់ប្រភេទ
-អាជីវកម្មផ្នែកទេសចរណ៍ ដូចជាសណ្ឋាគារ ភោជនីយដ្ឋាន និងមណ្ឌលកំសាន្ត
-អាជីវកម្មប្តូរប្រាក់
-សេវាផ្សាយពាណិជ្ជកម្ម និងបោះពុម្ពផ្សាយ

៦- ថិរវេលា : ៩៩ ឆ្នាំ

p

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

ភឹម_ស៊ីថន

ចម្លងជូន
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

សស។ - ឯកសារ - កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ .... ពណ.ចបព

ភ្នំពេញថ្ងៃទី ...... ខែ ...... ឆ្នាំ ២០......

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ជំរាបមក

លោក **លី ភក្តី** ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន **ជូន តិចថាយល៍**

អាសយដ្ឋានៈ មហាវិថីសហព័ន្ធរុស្ស៊ី បូរី១០០ខ្នង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

កម្មវត្ថុ : ករណីសុំកែប្រែ និងតំកលទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ជូន តិចថាយល៍**
JUNE TEXTILES CO., LTD.

យោង : -សំណើរបស់ក្រុមហ៊ុន ចុះថ្ងៃទី ១១ - ១១- ២០១០
-សេចក្តីសំរេចរបស់ក្រុមហ៊ុនមេ ចុះថ្ងៃទី ០៦ -១០ - ២០១០
-លិខិតរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាលេខ ២២៣៣/១០ គ.វ.ក ចុះថ្ងៃទី ០៣ -១១- ២០១០
-តារាងបញ្ជាក់ការផ្ទេរ និងទទួលភាគហ៊ុន ចុះថ្ងៃទី ០៦ ១០- ២០១០
-តារាងបែងចែកភាគហ៊ុនថ្មី ចុះថ្ងៃទី ០៦- ១០- ២០១០
-លក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុនចុះហត្ថលេខា ថ្ងៃទី ០៦- ១០- ២០១០
-សេចក្តីប្រកាសស្តីពីការកែប្រែលក្ខន្តិកៈក្រុមហ៊ុនក្នុងព្រឹត្តិប័ត្រពាណិជ្ជកម្មលេខ ៨២៧
ចេញផ្សាយថ្ងៃទី ១៥ - ១២ - ២០១០

តាមកម្មវត្ថុនិងយោងខាងលើនេះ ខ្ញុំសូមជំរាបលោកថា ៖ ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីនូវការកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ជូន តិចថាយល៍** JUNE TEXTILES CO., LTD. ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Inv. 290/97E ចុះថ្ងៃទី 13 - 01 - 1997 ទៅតាមចំណុចដូចមានចែងក្នុងលិខិតស្នើ និងយោងខាងលើគឺៈ

-ការបញ្ចូលសមាជិកហ៊ុនថ្មី ចំនួន ០២ រូប គឺលោក **លី ភក្តី** និងលោក **ម៉ា សំណាង**
-ការធ្វើអនុប្បទានភាគហ៊ុន
-សមាសភាពសមាជិកហ៊ុនថ្មី :
-ក្រុមហ៊ុន RB (LABUAN) LTD តំណាងដោយលោក LEE THAI KHIT (យោងព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៣៧៧ ចុះថ្ងៃទី ១៩ - ១២ - ២០០៨ បានផ្តល់សញ្ជាតិខ្មែរ ដល់លោក LEE THAI KHIT និងប្តូរឈ្មោះ មកជា **លី ភក្តី** (LEE PHEAKDEY)
កាន់កាប់ភាគហ៊ុនចំនួន ១២២.៥០០ ភាគហ៊ុន
-លោក **លី ភក្តី** (សញ្ជាតិ : ខ្មែរ) កាន់កាប់ភាគហ៊ុនចំនួន ៦៥.០០០ ភាគហ៊ុន
-លោក **ម៉ា សំណាង** (សញ្ជាតិ : ខ្មែរ) កាន់កាប់ភាគហ៊ុនចំនួន ៦២.០០០ ភាគហ៊ុន
-ការតែងតាំងក្រុមប្រឹក្សាភិបាលថ្មី:
-លោក **លី ភក្តី** ប្រធានក្រុមប្រឹក្សាភិបាល
-លោក **ម៉ា សំណាង** អភិបាល

p

-ការប្តូរទ្រង់ទ្រាយក្រុមហ៊ុនពីសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត ទៅជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

-ការប្តូរសញ្ជាតិក្រុមហ៊ុន :

ពីសញ្ជាតិ : បរទេស

មកសញ្ជាតិ : ខ្មែរ

និងប្តូរអត្តលេខចុះបញ្ជីពាណិជ្ជកម្មពី Inv. 290/97E ចុះថ្ងៃទី 13 - 01 - 1997 ទៅជា Inv. 290KH/1997 ចុះថ្ងៃទី 11 - 11 - 2010 ឯវិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ ៣៨២៣ ពណ.ចបព ចុះថ្ងៃទី ១៦ - ០៧ - ២០០៨ របស់ក្រសួងពាណិជ្ជកម្មត្រូវចាត់ទុកជានិរាករណ៍ ។

ប៉ុន្តែក្រុមហ៊ុនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ បើប្រសិនជាមានការតវ៉ាណាមួយទាក់ទងនឹងការកែប្រែលក្ខន្តិកៈក្រុមហ៊ុននេះ ។

អាស្រ័យហេតុនេះ សូមលោកជ្រាប និងអនុវត្តស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

[illegible]_ស៊ីថន

<u>ចម្លងជូន</u> :

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងបរិស្ថាន
-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
-សាលារាជធានីភ្នំពេញ
-មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
សន -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៩៤៣៧ **ពណ.ចបព**

ភ្នំពេញថ្ងៃទី ១៧ **ខែ** ធ្នូ **ឆ្នាំ** ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ជំរាបមក

លោក TIMOTHY MARK AMSTUTZ ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន **ក្រេឌីត លីមីធីត**
អាសយដ្ឋាន: លេខ ៧១ ផ្លូវលេខ ១៦៣ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

កម្មវត្ថុ : ករណីសុំកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ក្រេឌីត លីមីធីត** CREDIT LIMITED (Cambodia Rural Economic Development Initiatives for Transformation)

យោង : -សំណើរបស់ក្រុមហ៊ុនលេខ ២៥៧/១០ CREDIT HQ ចុះថ្ងៃទី ២៣ - ១០ - ២០១០
-លិខិតលេខ ធ៧.១០.៧៨ ឆត ចុះថ្ងៃទី ០៦ - ០៥ - ២០១០ របស់ធនាគារជាតិនៃកម្ពុជា
-លិខិតលេខ ធ៧.១០.៥៣ ឆត ចុះថ្ងៃទី ២៦ - ០៣ - ២០១០ របស់ធនាគារជាតិនៃកម្ពុជា
-លិខិតលេខ ធ៧.០៨.២៦៦ ឆត ចុះថ្ងៃទី ២៦ - ១២ - ២០០៨ របស់ធនាគារជាតិនៃកម្ពុជា
-លិខិតលេខ ធ៧.០៨.១៩៣ ឆត ចុះថ្ងៃទី ២៥ - ០៩ - ២០០៨ របស់ធនាគារជាតិនៃកម្ពុជា
-លក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុនចុះហត្ថលេខា ថ្ងៃទី ២៥ - ០៨ - ២០០៩
-សេចក្តីប្រកាសស្តីពីការកែប្រែលក្ខន្តិកៈក្រុមហ៊ុនក្នុងព្រឹត្តិប័ត្រពាណិជ្ជកម្មលេខ ៨២៦ ចេញផ្សាយថ្ងៃទី ៣០ - ១១ - ២០១០

តាមកម្មវត្ថុនិងយោងខាងលើនេះ ខ្ញុំសូមជំរាបលោកថា : ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីនូវការកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ក្រេឌីត លីមីធីត** CREDIT LIMITED (Cambodia Rural Economic Development Initiatives for Transformation) ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 1700/03E ចុះថ្ងៃទី 30 - 04 - 2003 ទៅតាមចំណុចដូចមានចែងក្នុងលិខិតស្នើ និងយោងខាងលើគឺ:

-ការប្តូរទីស្នាក់ការក្រុមហ៊ុន :
ទីស្នាក់ការចាស់ : លេខ ១៨ ផ្លូវលេខ ៤២២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
មកទីស្នាក់ការថ្មី : លេខ ៧១ ផ្លូវលេខ ១៦៣ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ

- ការបង្កើនដើមទុនចុះបញ្ជីពាណិជ្ជកម្ម :
-ដើមទុនចាស់ : ២.០០០.០០០.០០០ រៀល
-ដើមទុនថ្មី : ១១.២២១.២០០.០០០ រៀល

-បង្កើនចំនួនភាគហ៊ុនពី ១០.០០០ ភាគហ៊ុន ដល់ ៥៦.១០៦ ភាគហ៊ុន ដែល១ភាគហ៊ុន មានតំលៃ ២០០.០០០ រៀល

p

-ការប្តូរអ្នកតំណាងរបស់ក្រុមហ៊ុន WORLD RELIEF CORPORATION (នីតិបុគ្គលម្ចាស់ហ៊ុន)
ពីលោក KENNETH LEE GRABER មកលោក STEPHAN JAMES BAUMAN វិញ

-សមាសភាពសមាជិកហ៊ុនថ្មី :

- ក្រុមហ៊ុន WORLD RELIEF CORPORATION កាន់កាប់ភាគហ៊ុនចំនួន ៨៥.៨១៨ ភាគហ៊ុន
- ក្រុមហ៊ុន WORLD RELIEF CANADA កាន់កាប់ភាគហ៊ុនចំនួន ៧.១៧៨ ភាគហ៊ុន
- ក្រុមហ៊ុន WORLD HOPE INTERNATIONAL កាន់កាប់ភាគហ៊ុនចំនួន ៣.១១៨ ភាគហ៊ុន

-សមាសភាពក្រុមប្រឹក្សាភិបាលថ្មី:

- លោក TIMOTHY MARK AMSTUTZ "គតិយជន" ប្រធានក្រុមប្រឹក្សាភិបាល
- កញ្ញា **អ៊ុំ ច័ន្ទរ៉ូនី** "គតិយជន" អភិបាល
- លោកស្រី SREY HEM ROBERTS "គតិយជន" អភិបាល
- លោក GREGG BUCKMAN BURGESS "គតិយជន" អភិបាល
- លោកស្រី **ឆា ច័ន្ទសុធារី** "គតិយជន" អភិបាល
- លោក FONG KUM CHOY "គតិយជន" អភិបាល
- លោក SAMMY TANWAN MAH "គតិយជន" អភិបាល

ប៉ុន្តែក្រុមហ៊ុនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ប្រសិនជាមានការតវ៉ាណាមួយទាក់ទង នឹងការកែប្រែលក្ខន្តិកៈក្រុមហ៊ុននេះ ។

អាស្រ័យហេតុនេះ សូមលោកជ្រាប និងអនុវត្តស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

ភឹម_ស៊ីថន

<u>ចម្លងជូន</u> :

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ធនាគារជាតិនៃកម្ពុជា
-អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
-សាលារាជធានីភ្នំពេញ
-មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
ល៥ -ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៤២៣១ ពណ.ចបព

ភ្នំពេញថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ជំរាបមក

លោក KIM NAM KYUN ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន **អិម អ៊ី ភី (ខេមបូឌា)**
អាសយដ្ឋាន: លេខ ១៣៨ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

កម្មវត្ថុ : ករណីសុំកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **អិម អ៊ី ភី (ខេមបូឌា)** MEP (CAMBODIA) Co., Ltd.

យោង : -សំណើរបស់ក្រុមហ៊ុន ចុះថ្ងៃទី ១៨ - ១១ - ២០១០
-កំណត់ហេតុអង្គប្រជុំ និងសេចក្តីសំរេចសមូហភាព ចុះថ្ងៃទី ១៧ - ១១ - ២០១០
-លក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុនចុះហត្ថលេខា ថ្ងៃទី ១៧ - ១១ - ២០១០
-សេចក្តីប្រកាសស្តីពីការកែប្រែលក្ខន្តិកៈក្រុមហ៊ុនក្នុងព្រឹត្តិប័ត្រពាណិជ្ជកម្មលេខ ៤២៧ ចេញផ្សាយថ្ងៃទី ១៥ - ១២ - ២០១០

តាមកម្មវត្ថុនិងយោងខាងលើនេះ ខ្ញុំសូមជំរាបលោកថា : ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីនូវការកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **អិម អ៊ី ភី (ខេមបូឌា)** MEP (CAMBODIA) Co., Ltd. ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. 12740/08P ចុះថ្ងៃទី 03 - 10 - 2008 ទៅតាមចំណុចដូចមានចែងក្នុងលិខិតស្នើ និងយោងខាងលើគឺ:

-ការលាលែងចេញសមាជិកហ៊ុនចំនួន០១រូប គឺលោក **អឿន ហៀម** " អភិបាលចាស់ "
-ការបញ្ចូលសមាជិកហ៊ុនថ្មី ចំនួន ០១រូប គឺលោក **គីម យ៉ុងស៊ុ**
-ការធ្វើអនុប្បទានភាគហ៊ុន
-សមាសភាពសមាជិកហ៊ុនថ្មី :
- -លោក KIM NAM KYUN (សញ្ជាតិ : កូរ៉េ) កាន់កាប់ភាគហ៊ុនចំនួន ៣៩០ ភាគហ៊ុន
- -លោក **គីម យ៉ុងស៊ុ** (សញ្ជាតិ : ខ្មែរ) កាន់កាប់ភាគហ៊ុនចំនួន ៥១០ ភាគហ៊ុន
- -ក្រុមហ៊ុន MIRAE EQUITY PARTNERS CO., LTD. កាន់កាប់ភាគហ៊ុនចំនួន ១០០ ភាគហ៊ុន

-ការតែងតាំងក្រុមប្រឹក្សាភិបាលថ្មី:
- -លោក KIM NAM KYUN ប្រធានក្រុមប្រឹក្សាភិបាល
- -លោក **គីម យ៉ុងស៊ុ** អភិបាល

p

ប៉ុន្តែក្រុមហ៊ុនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ប្រសិនជាមានការតវ៉ាណាមួយទាក់ទងនឹងការកែប្រែលក្ខន្តិកៈក្រុមហ៊ុននេះ ។

អាស្រ័យហេតុនេះ សូមលោកជ្រាប និងអនុវត្តស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចាម ប្រសិទ្ធ

<u>ចម្លងជូន</u> :

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងបរិស្ថាន
-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ធនាគារជាតិនៃកម្ពុជា
-ក្រសួងសុខាភិបាល
-ក្រសួងពត៌មាន
-ក្រសួងសាធារណការ និងដឹកជញ្ជូន
-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
-ក្រសួងអប់រំយុវជន និងកីឡា
-ក្រសួងទេសចរណ៍
-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
-អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
-មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
-ឯកសារ-កាលប្បវត្តិ

p

p

បោះពុម្ពនៅអគ្គនាយកដ្ឋាន

រាជកិច្ច និង សេវាកុំព្យូទ័រ

នៃ ទីស្តីការគណៈរដ្ឋមន្ត្រី